ជ្រើសរើសធម្មជាតិ
Choose Natural

actionaid



កសិកម្មធម្មជាតិ
កសិកម្មក្រៅប្រព័ន្ធ

កសិករខ្នាតតូចបង្កើនលទ្ធភាពប្រើប្រាស់ទឹកសម្រាប់ដំណាំកសិកម្ម

ដោយផ្អែកលើបទពិសោធន៍ក្នុងឆ្នាំ ២០១៦ នៅក្នុងខេត្តកំពត និងខេត្តកំពង់ធំ ប្រជាពលរដ្ឋបានជួបប្រទះផលប៉ះពាល់នៃបាតុភូតអែល នីណូ (El Nino) លើជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ គ្រោះរាំងស្ងួតនេះបានធ្វើឱ្យមានបញ្ហាកង្វះទឹកទាំងនៅក្នុងសាលារៀន និងក្នុងភូមិរបស់សហគមន៍នៅតាមជនបទ។ ជាទូទៅ កសិករគោលដៅតែងជួបការលំបាកក្នុងការប្រើប្រាស់ទឹកសម្រាប់ដំណាំកសិកម្ម និងការប្រើប្រាស់ប្រចាំថ្ងៃក្នុងអំឡុងពេលគ្រោះរាំងស្ងួត (កម្ពុ:-ឧសភា)។ នៅពេលដែលគ្រោះរាំងស្ងួតកើតឡើង ស្ត្រីគឺជាក្រុមដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ ដោយសារតែស្ត្រីត្រូវការចំណាយពេលច្រើនក្នុងការងារកសិកម្ម និងការងារផ្ទះ។ ក្រៅពីនេះ ចំណេះដឹងរបស់កសិករដែលជាស្ត្រីលើបច្ចេកទេសកសិកម្មនៅមានកម្រិតនៅឡើយ។

ដើម្បីដោះស្រាយបញ្ហាគ្រោះរាំងស្ងួត ក៏ដូចជាការរួមចំណែកបង្កើនលទ្ធភាពទទួលបានទឹកប្រើប្រាស់សម្រាប់កសិករខ្នាតតូចនៅក្នុងតំបន់ដែលងាយរងគ្រោះដោយគ្រោះរាំងស្ងួត អង្គការអាក់សិនអេតកម្ពុជាបានធ្វើការជាមួយអង្គការដៃគូក្នុងស្រុកចំនួនបី រួមមានមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីនៅកម្ពុជា (CWDCC) ក្នុងខេត្តកំពត អង្គការសង្គ្រោះជនទុរគតនិងមនុស្សចាស់ (HOM) និងអង្គការសហប្រតិបត្តិការដើម្បីកាត់បន្ថយភាពក្រីក្រ (COFAP) ក្នុងខេត្តកំពង់ធំ និងក្រុមហ៊ុនសូឡាបូមទឹក។



តាមរយៈការអន្តរាគមន៍របស់គម្រោង កសិករខ្នាតតូចត្រូវបានជ្រើសរើស និងបង្កើតជាក្រុមផលិត ដើម្បីអនុវត្តបច្ចេកទេសកសិកម្មក្សេត្រវិស្ថាន និងបញ្ជូនផលិតផលរបស់ពួកគេទៅកាន់ទីផ្សារតាមរយៈភ្នាក់ងារស្ត្រីទីផ្សារ(WMA)។ ដើម្បីសម្រេចបានទូរលទ្ធផលនេះគម្រោងបានអនុវត្តសកម្មភាពដូចជា រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងសមាជិកក្រុមផលិត ដំឡើងប្រព័ន្ធសូឡាបូមទឹក ចែកតង់សម្រាប់ស្តុកទឹក ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្មនិងគោលការណ៍កសិកម្មក្សេត្រវិស្ថាន ចងក្រងនិងបង្កើតគណៈកម្មាធិការក្រុមអ្នកប្រើប្រាស់ទឹកដែលពួកគាត់ទទួលបានវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងប្រើប្រាស់ទឹក ព្រមទាំងគោលការណ៍ និងលក្ខខន្តិកៈផ្សេងៗ។

ជាលទ្ធផល កសិករខ្នាតតូចចំនួន៦៨នាក់ រួមទាំងសមាជិកគ្រួសារចំនួន ៣០២នាក់ ទទួលបានលទ្ធភាពប្រើប្រាស់ទឹកបានងាយស្រួលជាងមុន សូម្បីតែក្នុងរដូវប្រាំង ក៏ពួកគេអាចស្តុកទឹកបានគ្រប់គ្រាន់ក្នុងអំឡុងពេលគ្រោះរាំងស្ងួតឬមានបាតុភូតកង្វះទឹកណាមួយកើតឡើង ព្រមទាំងអាចបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ ក្រៅពីនេះ វាក៏បានជួយកសិករកាត់បន្ថយចំណាយលើប្រេងសាំង ឬអគ្គិសនី ដើម្បីបូមទឹកសម្រាប់ដាំដំណាំ ចំណេញពេលវេលា និងកាត់បន្ថយកម្លាំងពលកម្មលើការងារធ្វើកសិកម្ម ព្រមទាំង បង្កើនលទ្ធភាពប្រើប្រាស់ទឹកសម្រាប់ការដំណាំ និងប្រើប្រាស់ក្នុងគ្រួសារ សម្រាប់ការរស់នៅអំឡុងពេលគ្រោះរាំងស្ងួត។

តាមរយៈលទ្ធភាពទទួលបានទឹកប្រើប្រាស់ និងតង់ប្រសើរជាងមុន កសិករខ្នាតតូចមានឪកាសបង្កើនការដាំដុះបានច្រើនប្រភេទ និងធ្វើកសិកម្មចម្រុះ ហើយពួកគាត់ក៏អាចចិញ្ចឹមត្រីនៅក្នុងតង់ដែលទទួលបានពីគម្រោងផងដែរ។ យោងតាមលោក ខន ឆេងលី ក្រុមប្រឹក្សាឃុំទី១ នៃឃុំដីក្រហមបានលើកឡើងថា **“ជាក់ស្តែង កសិកររាមានការរំភើប និងរីករាយយ៉ាងខ្លាំងចំពោះសកម្មភាពអនុវត្តគម្រោងក្នុងសហគមន៍ដែលផ្តល់ អត្ថប្រយោជន៍យ៉ាងសំខាន់ និងជួយកសិករក្នុងការបង្កើនលទ្ធភាពប្រើប្រាស់ទឹកទាំងការផលិតដំណាំ ឬការប្រើប្រាស់សម្រាប់ការងារផ្ទះក្នុងអំឡុងពេលគ្រោះរាំងស្ងួតបានល្អប្រសើរជាងពេលមុនៗ។ ជារួម កសិករបានបង្កើនផលិតភាព និងប្រាក់ចំណូលបានច្រើនជាងមុន ពិសេស រាបានរួមចំណែកលើកកម្ពស់ជីវភាពកសិករ និងកាត់បន្ថយចំណាកស្រុករបស់កសិករផងដែរ”**។

ថាមពលសូឡាគឺជាថាមពលកកើតឡើងវិញដែលបានបង្កើនអត្ថប្រយោជន៍យ៉ាងច្រើនដល់សហគមន៍ ចូលរួមចំណែកដល់សេដ្ឋកិច្ចជាតិ និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេស។ ដូច្នេះហើយ ប្រព័ន្ធម៉ាស៊ីនបូមទឹកដោយថាមពលសូឡាគឺមានប្រយោជន៍ និងជាមធ្យោបាយដ៏ល្អបំផុតក្នុងការសន្សំសំចៃថាមពលនិងទឹក ពេលវេលា ការចំណាយ និងកម្លាំងពលកម្ម ជាពិសេសការពារបរិស្ថាន និងលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍។ ក្រៅពីនេះ វាបានជួយសម្រួល និងលើកកម្ពស់ដល់ស្ត្រីឬស្ត្រីវ័យចំណាស់ឱ្យចូលរួមការងារកសិកម្មបន្ថែមទៀត។





ការចិញ្ចឹមមាន់ដែលមានភាពធន់តាមរយៈការអនុវត្តបែបក្សេត្រវិស្ថាន

“ហត់នឿយបន្តិចមែន ប៉ុន្តែទទួលបានកសិផលមានសុវត្ថិភាពសម្រាប់គ្រួសារ និងអ្នកប្រើប្រាស់នៅជុំវិញខ្លួន” លោក កើន ហំ មានវ័យ២៧ឆ្នាំ សព្វថ្ងៃប្រកបមុខរបរជាកសិករ ស្ថិតនៅភូមិ ផ្លោង ឃុំបឹងក្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង។

លោក កើន ហំ បានចាប់ផ្តើមចិញ្ចឹមមាន់តាំងពីឆ្នាំ ២០១៥។ កសិករជាច្រើនរួមទាំងលោក ដែលប្រកបមុខរបរចិញ្ចឹមមាន់នេះបានជួបប្រទះផលវិបាកមួយចំនួន។ ជាធម្មតា អាកាសធាតុនៅកម្ពុជាមានលក្ខណៈក្តៅ ហើយសើម ដែលកំដៅអាចនឹងកើនឡើងកាន់តែខ្លាំងនៅចន្លោះខែមីនា និងខែមេសា។ ម្យ៉ាងទៀត នៅក្នុងរដូវក្តៅចាប់ពីខែតុលាដល់ខែមេសា ការផលិតចំណីរបស់មាន់អាចថយចុះយ៉ាងខ្លាំង។ នៅពេលដែលភ្លៀងដើមឆ្នាំចាប់ផ្តើមធ្លាក់ វាបណ្តាលឱ្យសត្វមាន់របស់គាត់ភាគច្រើនស្លាប់ដោយសារជំងឺមួយចំនួន។

ទន្ទឹមនឹងនោះ គាត់បានបាត់បង់មាន់ទាំងអស់ នៅពេលដែលជម្ងឺកូវីដ១៩ផ្ទុះឡើង គាត់ក៏បាក់ទឹកចិត្ត ហើយសម្រេចចិត្តចាឈប់ចិញ្ចឹមមាន់ទៀត ហើយមកធ្វើការជាកម្មករសំណង់នៅក្នុងភូមិវិញ ដើម្បីផ្គត់ផ្គង់គ្រួសាររបស់គាត់។





នៅឆ្នាំ ២០២២ ស្ត្រីឆ្នើមនៅខេត្តកោះកុងបានផ្តល់ពូជមាន់ដល់សហគមន៍ដោយប្រើជំនួយក្រោមសកម្មភាពរបស់គម្រោង **“ជម្រើសដឹកនាំដោយស្ត្រីដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា”**។

លោក កើន ហំ គឺជាកសិករម្នាក់ក្នុងចំណោមកសិករដែលទទួលបានការគាំទ្រពីក្រុមស្ត្រីឆ្នើម។ គាត់បានទទួលមេមាន់ចំនួនប្រាំពីរក្បាល និងសម្ភារមួយចំនួនដូចជាទ្រុងសម្រាប់កូនមាន់ និងគ្រាប់ពូជបន្លែជាដើម។ មិនត្រឹមតែប៉ុណ្ណោះ លោកក៏បានទទួលការបណ្តុះបណ្តាលបច្ចេកទេស លើដំណោះស្រាយចំពោះបញ្ហាប្រឈមក្នុងការចិញ្ចឹមសត្វនៅក្រោមលក្ខខណ្ឌអាកាសធាតុបែបនេះ រួមមានការផ្តល់ប្រភពទឹកដែលអាចទុកចិត្តបានហើយស្អាត មានម្លប់គ្រប់គ្រាន់ ការបាញ់ទឹកទៅលើបរិវេណដែលមាន់នៅឱ្យជោគល្មមនៅពេលព្រឹក និងពេលល្ងាចដើម្បីរក្សាសំណើមដី និងការត្រាំដើមបណ្តូលពេជ្រ ឬសំបកគ ឬគល់ស្លឹកគ្រៃ ឬសំបកស្តៅឲ្យមាន់ផឹកជាប្រចាំ។



លោកបានបញ្ជាក់ថា៖ **“ខ្ញុំបានបង្កើនទុនមេមាន់ជាង២០ក្បាល។ ហើយមេមាន់មួយក្បាលអាចសល់កូនប្រហែល៨ក្បាល តាមរយៈការខិតខំមើលថែដិតដល់។ ខ្ញុំលក់មាន់បានចំនួនពីរលើក លើកទីមួយខ្ញុំលក់បានចំនួន២០គីឡូក្រាម ហើយលើកទីពីរបានចំនួន ៣០គីឡូក្រាមទៀត ដោយក្នុងមួយគីឡូខ្ញុំលក់បានក្នុងតម្លៃ ២,៦០០០រៀល”**។

គាត់បានប្រាប់ពួកយើងដោយក្តីសប្បាយរីករាយថា៖ **“សព្វថ្ងៃនេះ ជីវភាពគ្រួសារខ្ញុំកាន់តែមានភាពល្អប្រសើរឡើង ដោយ សារយើងរកចំណូលបានជាប់លាប់”។ ជាចុងក្រោយគាត់ចង់ស្នើសុំការបណ្តុះបណ្តាលបន្ថែមលើការការពារបក្សីពីការឆ្លងជម្ងឺផ្សេងៗ”**។

ការផ្លាស់ប្តូរក្នុងជីវិតរបស់កសិករតាមរយៈការអនុវត្តគោលការណ៍ក្បែរត្របរិស្ថាន

អ្នកស្រី ជា សាវៃ អាយុ៣៨ឆ្នាំ មានកូន២នាក់ រស់នៅភូមិ៣មគ្រែងង ឃុំក្តីដូង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ សព្វថ្ងៃ អ្នកស្រីប្រកបមុខរបរជាកសិករ។

ដូចជាកសិករក្នុងប្រទេសកម្ពុជាដទៃទៀតដែរ អ្នកស្រីបានជួបការលំបាកជាច្រើន។ បញ្ហាចម្បងដែលអ្នកស្រីជួបប្រទះគឺកង្វះទឹក និងការកើនឡើងតម្លៃជី ដែលជាកត្តារាំងដល់ផលិតកម្មកសិកម្ម។ ដោយសារបញ្ហាដែលកើតឡើងនេះហើយ បានធ្វើឱ្យផលិតផលកសិកម្មរបស់គាត់ធ្លាក់ចុះ ហើយដំណាំភាគច្រើនរបស់គាត់ត្រូវបានសត្វល្អិតបំផ្លាញ។ ក្រៅពីនេះ អ្នកស្រីក៏ប្រឈមនឹងបញ្ហាដីកជញ្ជូនផងដែរ ដោយសារគាត់ត្រូវធ្វើដំណើរផ្លូវឆ្ងាយជាមួយនឹងកូនស្រីរបស់គាត់ដែលនៅតូច ទៅកាន់ផ្សារដែលមានចំងាយប្រហែល ១០គីឡូម៉ែត្រពីផ្ទះរបស់គាត់។

នៅពេលព្រឹក អ្នកស្រី សាវៃ ធ្វើការងារផ្ទះមួយចំនួន រួចរៀបចំផលដំណាំដែលប្រមូលបានទៅលក់នៅផ្សារ។ ជីវភាពរបស់គាត់មានភាពលំបាកខ្លាំង ដោយសារគាត់អាចរកចំណូលបានត្រឹមតែ ២០០០០រៀល ស្មើនឹង ៥ដុល្លារក្នុងមួយខែ។ គាត់ចាំបានថា មានពេលមួយដែលគាត់មិនមានលុយនាំកូនស្រីទៅមន្ទីរពេទ្យ ដោយសារតែគាត់មានចំណូលតិចតួច ហើយគាត់ក៏ខ្ចីលុយពីអ្នកដទៃមិនបានទៀត។ នៅពេលនោះ គាត់មានអារម្មណ៍អស់សង្ឃឹមនឹងខ្លួនឯងជាខ្លាំង។



គាត់បានចូលរួម និងស្វែងយល់អំពីការអនុវត្តកសិកម្មតាមរយៈគម្រោងដែលបានអនុវត្តនៅក្នុងសហគមន៍ ដោយមានការគាំទ្រពីអង្គការសហប្រតិបត្តិការដើម្បីកាត់បន្ថយភាពក្រីក្រ(COFAP) តាំងពីឆ្នាំ ២០១៨។ ពេលនោះ គាត់បានទទួលការបណ្តុះបណ្តាលស្តីពីបច្ចេកទេសដាំដុះ ផែនការកសិកម្ម ការធ្វើជីកំប៉ុស្តទឹកនិងគោក ការកម្ចាត់សត្វល្អិត និងវគ្គបណ្តុះបណ្តាលផ្សេងទៀតដែលផ្តល់ជាប្រយោជន៍ក្នុងការបង្កើនចំណេះដឹង និងជីវភាពរស់នៅរបស់គាត់។ ទន្ទឹមនឹងនេះ គាត់ក៏បានយល់ដឹងបន្ថែមពីបច្ចេកទេស និងជំនាញថ្មីៗ ព្រមទាំងទទួលបានគ្រាប់ពូជដំណាំ ការប្រើប្រាស់សូឡាបូមទឹក និងតង់ផងដែរ។

ក្នុងពេលបច្ចុប្បន្ននេះ ស្ថានភាពគ្រួសាររបស់គាត់មានភាពប្រសើរឡើងជាងមុន ហើយអ្នកស្រីបានចែករំលែកថា **"ការផ្លាស់ប្តូរដែលគួរឱ្យកត់សម្គាល់បន្ទាប់ពីខ្ញុំបានទទួលការបណ្តុះបណ្តាលពីអង្គការគឺ ចំណេះដឹង និងការអនុវត្តកសិកម្មដាំដំណាំរបស់ខ្ញុំ។ បន្ថែមពីនេះទៀត ខ្ញុំដឹងពីការបង្កើន និងគ្រប់គ្រងដំណាំរបស់ខ្ញុំដោយមិនប្រើជីគីមី។ ក្រៅពីនេះខ្ញុំក៏យល់កាន់តែច្បាស់អំពីបញ្ហាសុខភាព អនាម័យ យេនឌ័រ និងផែនការដាំដុះបន្ថែម"។** គាត់បានបន្ថែមថា៖ **"ខ្ញុំរកចំណូលបានច្រើនជាងមុន ហើយឥឡូវនេះ ខ្ញុំមានលុយគ្រប់គ្រាន់សម្រាប់សង់ផ្ទះថ្មី ទិញដី និងម៉ូតូថ្មីមួយគ្រឿងថែមទៀតផង"**។

នៅពេលដែលការផលិត និងចំណេះដឹងរបស់គាត់មានការប្រសើរជាងមុន គាត់ក៏បានចូលរួម និងរួមចំណែកចែករំលែកដល់សហគមន៍អំពីបទពិសោធន៍ ការរៀនសូត្រ និងការបណ្តុះគ្រាប់ពូជដល់សមាជិកសហគមន៍ផ្សេងៗ។ គាត់ក៏បាននិយាយផងដែរថា **"ខ្ញុំពិតជាអរគុណ និងកើតសរសើរចំពោះការគាំទ្ររបស់អង្គការ ទាំងផ្លូវចិត្ត ទាំងផ្តល់នូវ ចំណេះដឹង ធនធាន ការផ្តត់ផ្តង់ និងអ្វីៗជាច្រើនទៀតដើម្បីជួយដល់កសិករដូចជាខ្ញុំ"**។ បន្ថែមពីនេះ គាត់សង្ឃឹមថាអង្គការនៅតែគាំទ្រ ដើម្បីជួយអភិវឌ្ឍសហគមន៍ឱ្យកាន់តែប្រសើរឡើង។ ក្តីស្រមៃរបស់អ្នកស្រីមិនឈប់នៅត្រឹមនេះនោះទេ គាត់ចង់ពង្រីកដីដាំដុះបន្ថែម និងទិញរ៉ឺម៉ក និងឡាន ដើម្បីដឹកបន្លែទៅលក់នៅទីផ្សារ និងតាមខេត្តផ្សេងៗ។



បទពិសោធន៍របស់ សុខ ជា ក្នុងការអនុវត្តកសិកម្មឱ្យមានភាពប្រសើរជាងមុន

អ្នកស្រី សុខ ជា មានអាយុ ៣៥ឆ្នាំ កូន២នាក់ រស់នៅភូមិបិណ្ដីយ៍ ឃុំព្រៃគុយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ គាត់ជាកសិករ ហើយពីមុន គាត់អាចរកចំណូលបានត្រឹមតែ ៧៥ ដុល្លារក្នុងមួយខែ។

អ្នកស្រី សុខ ជា បានរំលឹកថា ក្នុងរយៈពេល ២០ឆ្នាំចុងក្រោយនេះ អាកាសធាតុមិនសូវសមប្រកបសម្រាប់ការធ្វើកសិកម្ម ហើយគ្រោះធម្មជាតិ បានបង្កឱ្យផលិតផលដំណាំរបស់គាត់មានការធ្លាក់ចុះ។ ដោយសារតែគ្រោះរាំងស្ងួតក្នុងសហគមន៍ ពេលនោះ គាត់មិនមានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រពចំការរបស់គាត់នោះទេ។ ទោះបីជាភូមិរបស់គាត់មានអណ្ដូងក៏ដោយ ក៏គាត់មិនអាចប្រើប្រាស់ទឹកពីអណ្ដូងនោះបានដែរ ដោយសារទឹកនោះឡើងល្អក់ពណ៌ក្រហម។ ហើយ ការប្រែប្រួលអាកាសធាតុក៏បានធ្វើឱ្យដំណាំរងការខូចខាតដោយសារមានសត្វល្អិតផងដែរ។

ដោយមានការគាំទ្រពីអង្គការអាក់សិនអេតកម្ពុជា **(ActionAid Cambodia)** និងកិច្ចសហការរវាងអង្គការសង្គ្រោះជនទុរគតនិងមនុស្សចាស់ **(HOM)** ព្រមទាំងមេភូមិ ក្នុងភូមិគោលដៅ ក្នុងការជួសជុលប្រឡាយ និងអណ្ដូងនោះ ឥឡូវនេះលោកស្រីមានទឹកគ្រប់គ្រាន់សម្រាប់ធ្វើស្រែចម្ការ។ លើសពីនេះ គាត់ក៏ទទួលបានការប្រើប្រាស់សូឡាបូមទឹក គ្រាប់ពូជ និងសម្ភារកសិកម្មដូចជា ធើងសម្រាប់ដាំ តង់និងសម្ភារផ្សេងៗទៀត។ ជាងនេះទៅទៀត គាត់ក៏ទទួលបានវគ្គបណ្ដុះបណ្ដាលក្នុងការផលិតជីកំប៉ុស្ដ (ទឹក និងគោក) ការគ្រប់គ្រង និងកំចាត់សត្វល្អិត ព្រមទាំងបានទៅរៀនសូត្រដោយផ្ទាល់ពីអ្នកផលិតជីផងដែរ។



អ្នកស្រី សុខ ជា បាននិយាយថា **"ខ្ញុំចេះធ្វើទាំងជីកំប៉ុសទឹក និងគោក ហើយចេះជំនាញដាំដំណាំឱ្យបានប្រសិទ្ធភាពល្អ"។** លើសពីនេះ គាត់បានកត់សម្គាល់ថា៖ **"គ្រួសាររបស់ខ្ញុំអាចរកប្រាក់ចំណូលបានច្រើនជាងមុន ហើយខ្ញុំមានទំនាក់ទំនងល្អជាមួយកសិករផ្សេងទៀតដែលពួកយើងអាចរៀនសូត្រពីគ្នាទៅវិញទៅមកបាន។ លើសពីនេះ ខ្ញុំមានប្រាក់គ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ការសិក្សារបស់កូនៗរបស់ខ្ញុំ"**។

ជាចុងក្រោយ គាត់សូមអរគុណដល់អង្គការដែលផ្តល់ប្រព័ន្ធសូឡា និងតង់ដែលកែលម្អ និងបង្កើនផលិតផលរបស់គាត់។ ជាមួយគ្នានេះ លោកស្រីរំពឹងថា ក្រុមកសិករខ្នាតតូចនឹងទទួលបានការបណ្តុះបណ្តាលបន្ថែមលើបច្ចេកទេសដាំដុះ ការចិញ្ចឹមសត្វ និងការថែទាំប្រព័ន្ធសូឡាបូមទឹក។





ការផ្លាស់ប្តូររបស់ ស្រីពៅ បន្ទាប់ពីទទួលបានវគ្គបណ្តុះបណ្តាលទៅលើបច្ចេកទេសកសិកម្ម

អ្នកស្រី សៅ ស្រីពៅ មានអាយុ៤០ឆ្នាំ ប្រកបមុខរបរជាកសិករ រស់នៅក្នុងភូមិស្រែលារ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត។ គាត់មានកូនស្រីម្នាក់ និងកូនប្រុសម្នាក់ ហើយកូនៗរបស់គាត់កំពុងនៅក្នុងវ័យសិក្សា ហើយសព្វថ្ងៃ គាត់រកបានប្រាក់ចំណូលជាមធ្យមប្រហែល ៣០០ ដុល្លារក្នុងមួយខែពីការលក់បន្លែ និងស្រូវគ្រប់ប្រភេទដែលគាត់បានផលិត។

មុនពេលគាត់បានចូលរួមជាមួយកម្មវិធីរបស់អង្គការ គាត់បានប្រឈមមុខនឹងគ្រោះរាំងស្ងួត បញ្ហាសុខភាព និងកង្វះសមត្ថភាពក្នុងការពង្រឹងអាជីវកម្មរបស់គាត់។ ចំណែកឯប្រាក់ចំណូលរបស់គាត់ក៏នៅមានកម្រិតទាបផងដែរ ហើយគាត់តែងតែព្រួយបារម្ភពីបញ្ហាមិនមានប្រាក់គ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ការសិក្សារបស់កូនៗ។ ក្រៅពីគ្រោះរាំងស្ងួត ការប្រែប្រួលអាកាសធាតុក៏បានបង្កឱ្យមានកំណើនសត្វល្អិតដែលបំផ្លាញដំណាំ និងបង្កផលប៉ះពាល់ផងដែរ។ នៅពេលនោះ គាត់មានការលំបាកក្នុងការដោះស្រាយបញ្ហានេះណាស់ ព្រោះគាត់មានចំណេះដឹងតិចតួចក្នុងការដាំដុះនៅឡើយ។

អ្នកស្រីបានចូលរួមជាមួយនឹងមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីនៅកម្ពុជា(CWDCC) និងគម្រោងជំរុញទីផ្សារសម្រាប់កសិករខ្នាតតូច (AIMS) ក្នុងឆ្នាំ ២០១៨។ ដោយមានការគាំទ្រពី CWDCC និងអង្គការអាកសិនអេតកម្ពុជា (ActionAid Cambodia) គាត់បានចេះពីរបៀបធ្វើជី និងស្វែងរកទីផ្សារសម្រាប់ផលិតផលរបស់គាត់។



គាត់បានចែករំលែកថា **"ខ្ញុំបានទទួលការបណ្តុះបណ្តាលអំពីផែនការកសិកម្ម វិធីដាំដុះឱ្យទទួលបានទិន្នផលខ្ពស់ និងវិធីសាស្ត្របង្កើនប្រាក់ចំណូលបន្ថែមពីការលក់ផលិតផល ដែលខុសពីមុន គ្រួសារខ្ញុំដាំដុះបន្លែតែមួយទៅពីរប្រភេទសម្រាប់លក់តែក្នុងសហគមន៍ប៉ុណ្ណោះ។ ជាក់ស្តែង ខ្ញុំក៏បានទទួលការបណ្តុះបណ្តាលក្នុងការស្វែងរកទីផ្សារ និងការកសាងបណ្តាញទីផ្សារផងដែរ"**។ គាត់ក៏បានបន្ថែមទៀតថា គាត់បានទទួលអណ្តូងទឹកមួយ និងសូឡាបូមទឹកចល័ត ដែលគាត់អាចបូមទឹកសម្រាប់ស្រោចស្រពចម្ការបានលឿនជាងមុន។



អ្នកស្រីបានបញ្ជាក់បន្ថែមថា៖ **"បច្ចុប្បន្ន ក្រុមគ្រួសាររបស់ខ្ញុំបានរៀនសូត្រពីបទពិសោធន៍កន្លងមក ដូច្នេះយើងចាប់ផ្តើមមករៀនដាំដំណាំចម្រុះវិញ។ ជាលទ្ធផល ប្រាក់ចំណូលរបស់យើងបានកើនឡើងជារៀងរាល់ថ្ងៃរហូតដល់តសូរយើងអាចទិញដីសម្រាប់ពង្រីកការដាំដុះ និងសង់ផ្ទះបាន។ ម្យ៉ាងទៀត យើងក៏មានតូបលក់បន្លែនៅកំពត អតិថិជនអាចមកទិញនៅតូបដោយផ្ទាល់ ឬក៏នៅផ្ទះ និងនៅចម្ការបាន"**។





ចំណែកឯផែនការបន្ទាប់សម្រាប់អាជីវកម្មគ្រួសាររបស់គាត់ គាត់ចង់ដាំដំណាំចម្រុះ បង្កើតសួនឈើហូបផ្លែ ពង្រីករោងសំណាញ់ ចិញ្ចឹមត្រី និងបង្កើតទីផ្សារក្នុងតំបន់ ហើយដាក់ឈ្មោះវាថា **"បន្លែសហគមន៍"**។ បន្ថែមពីនេះ អ្នកស្រីសង្ឃឹមថា អង្គការនឹងផ្តល់វគ្គបណ្តុះបណ្តាល និងការណែនាំបន្ថែមអំពីបច្ចេកទេសចិញ្ចឹមសត្វ ដូចជាក្តាម បង្កង និងខ្យងជាដើម។

សារៈសំខាន់នៃការអនុវត្តកសិកម្មក្សេត្រវិស្ថាន

យើងទាំងអស់គ្នាដឹងហើយថា បញ្ហាការប្រែប្រួលអាកាសធាតុមានការវិវឌ្ឍឥតឈប់ឈរពីមួយឆ្នាំទៅមួយឆ្នាំ ហើយកំណើនកំដៅផែនដីជាសកល ធ្វើឱ្យរបបទឹកភ្លៀងប្រែប្រួលមិនទៀងទាត់ បង្កឱ្យមានជំនន់ទឹកភ្លៀង រីងគ្រោះរាំងស្ងួតក៏បង្កឱ្យមានកង្វះទឹកសម្រាប់ប្រើប្រាស់ និងស្រោចស្រព ព្រមទាំងធ្វើឱ្យមានកំណើនសត្វល្អិតបំផ្លាញដំណាំ។ ហេតុការណ៍ទាំងនេះផ្តល់ផលលំបាកដល់ការរស់នៅ និងការបង្កបង្កើនផលកសិកម្មរបស់ប្រជាកសិករ ពិសេសធ្វើឲ្យទិន្នផលរបស់កសិករដែលទទួលបានមានកម្រិតទាប និងមិនអាចផលិតបានពេញមួយឆ្នាំ។

អ្នកស្រី ទេស ៣៛ មានអាយុ៤៣ឆ្នាំ បច្ចុប្បន្ន អ្នកស្រីមានកូន៥នាក់ស្រី២នាក់។ បន្ទាប់ពីទទួលបានវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសដាំដុះដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងចូលរួមដំណើរទស្សនៈកិច្ចសិក្សារៀនសូត្រពីកសិករនៅក្នុងស្រុកសូទ្រនិគម ខេត្តសៀមរាបមក អ្នកស្រីបានយកបច្ចេកទេសថ្មីដែលបានរៀនសូត្រនេះទៅអនុវត្តលើការដាំដុះលើភនបានចំនួន៣ភន ដែលមានខ្នាតទទឹង១.២ម៉ែត្រ និងបណ្តោយ១៥ម៉ែត្រ។តាមរយៈការអនុវត្តន៍កសិកម្មតាមបែបក្សេត្រវិស្ថាន អ្នកស្រី ទេស ៣៛ ក៏បានបង្ហាញអារម្មណ៍សប្បាយចិត្ត និងក្តីរំពឹងខ្ពស់ចំពោះសមិទ្ធផលដែលទទួលបានពីបច្ចេកទេសថ្មីនេះ។ វាបានផ្តល់ភាពងាយស្រួលលើការងារដាំដុះ(លើធ្នើ) ងាយស្រួលថែទាំ ទទួលបានទន្និផលច្រើនជាងមុនបើធៀបនឹងការដាំមុនៗ ជាក់ស្តែងក្នុង១ធ្នើ អ្នកស្រីអាចលក់បន្លែបានក្នុងតម្លៃពី១៨ម៉ឺនរៀលទៅ ២០ម៉ឺនរៀល។ កន្លងមក គាត់មិនអាចដាំបានពេញមួយឆ្នាំទេ ជាពិសេសនៅចន្លោះខែកុម្ភៈនិងខែមីនា ខែសីហានិងខែតុលា ដោយសារអាកាសធាតុមិនអំណោយផល តែបច្ចេកទេសថ្មីនេះបានជួយបង្កើនផលិតភាពបានពេញមួយឆ្នាំ ហើយអ្នកស្រីក៏គ្រោងនឹងពង្រីកធ្នើដាំដុះចំនួន២ភនបន្ថែមទៀត។





បើនិយាយពីអត្ថប្រយោជន៍នៃការអនុវត្តកសិកម្មក្សេត្រប្រវិស្តានវិញ អ្នកស្រី ទេស ពៅ បានលើកឡើងថា៖ **“ការអនុវត្តដោយប្រើប្រាស់ជីធម្មជាតិ គ្មានជាតិគីមី ជួយឱ្យគ្រួសារមានសុខភាពល្អ មិនសូវមានជំងឺ កាត់បន្ថយចំណាយថវិកាក្នុងការព្យាបាល បង្កើនជីវភាពគ្រួសារ រីឯដំណាំមានការងាយស្រួលក្នុងការលក់ ទទួលបានលទ្ធផលល្អលើសពីការរំពឹងទុក ធ្វើឱ្យដីមានជីវជាតិល្អ ហើយធូរ ជាពិសេសជាងនេះទៅទៀតនោះ ជួយឱ្យប្រជាសហគមន៍មានសុខភាពល្អគ្រប់ៗគ្នាទៅពេលបានបរិភោគបន្លែដែលដាំដោយអនុវត្តតាមបែបក្សេត្រប្រវិស្តាន”**។

ឥឡូវនេះ អ្នកស្រី ទេស ពៅ មានសមត្ថភាព និងផែនការចែករំលែកចំណេះដឹង និងបច្ចេកទេសដាំដុះដោយអនុវត្តកសិកម្មតាមបែបក្សេត្របរិស្តានដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ បន្តទៅសហគមន៍ដើម្បីឱ្យពួកគេអាចអនុវត្តតាម។





សម្រាប់ព័ត៌មានបន្ថែមអំពីគោលការណ៍ក្សេត្រវិស្ថាន

កំពត

អង្គការមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីនៅកម្ពុជា (CWDCC)

ភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត

069 950 099 / 099 950 099

ភ្នំពេញ-ពោធិ៍សាត់

អង្គការអភិវឌ្ឍន៍សម្លេងសហគមន៍ (BCV)

#17A, ផ្លូវលេខ 468, សង្កាត់ទួលទំពូង 1, ខណ្ឌចំការមន, ភ្នំពេញ

012 307 027

ពោធិ៍សាត់

អង្គការសហគមន៍ អភិវឌ្ឍន៍មិត្តជនបទ (RFCD)

ភូមិទួលម្ទាក់ ឃុំអន្លង់ភ្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់

012 706 453

កំពង់ធំ

អង្គការសហប្រតិបត្តិការដើម្បីកាត់បន្ថយភាពក្រីក្រ (COFAP)

ភូមិដំរីជាន់ខ្លា សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ

012 491 540 / 098 491 540

កំពង់ធំ

អង្គការសង្គ្រោះជនទុរគតនិងមនុស្សចាស់ (HOM)

ភូមិក្តី សង្កាត់ព្រៃតាហ៊ូ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ

012 759 876

កោះកុង

អង្គការមជ្ឈមណ្ឌលមូលប្រហ្មវិហារធម៌ (MPC)

ភូមិត្រពាំង ឃុំស្រែអំបិល ស្រុកស្រែអំបិល ខេត្តកោះកុង

010 463 141 / 071 913 7575

